# មហាបដ្ឋាន

## សង្កិលិដ្ឋត្តិកះ

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **មហាចណ្ឌរ័ត្នខ្មែរ**

ព.ស.២៥៦៦ គ.ស.២០២៣

# គម្ពីរបដ្ឋាន

## សទ្ទិលិង្គត្តិកៈ

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ  មហាវណ្ណារ័ត្នខ្មែរ

ព.ស.២៥៦៦

| | |
|---|---|
| សៀវភៅឈ្មោះ | : **គម្ពីរបដ្ឋាន សទ្ធិលិដ្ឋត្តិកៈ** |
| ប្រមូលរៀបរៀងដោយ | : **មហាវណ្ណរ័ត្នខ្មែរ (Maha Vannrat Khmer)** |
| ពិនិត្យដោយ | : ភិក្ខុរតននាថ **មាស សាពួន** |
| | : ភិក្ខុអាយុទីឃោ **ឈួន សាទឿន** |
| | : ភិក្ខុសទ្ធាជនោ **ឈាក ឈឿន** |
| | : ភិក្ខុបញ្ញាទីបោ **ស្វ ឆក** |
| វាយអត្ថបទដោយ | : ព្រះមហាអគ្គធរោ **សាយ ឡាយី** |
| រចនាសៀវភៅ និងក្រប | : ភិក្ខុវិមលោ **សាន ថាទីន** |
| ទីកន្លែងធ្វើ | : វត្តឃោសិតារាម ភូមិគោកជួន ឃុំពួក ស្រុកពួក ខេត្តសៀមរាប |
| កាលបរិច្ឆេទ | : **ព.ស.២៥៦៦ គ.ស.២០២៣** |

# អារម្ភកថា

បច្ចុប្បន្ននេះ ការសិក្សាព្រះអភិធម្ម ក្នុងប្រទេសកម្ពុជានៃយើងទាំងឡាយមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយ មានពុទ្ធបរិស័ទយកចិត្តទុកដាក់ក្នុងការរៀន ការសិក្សាស្វែងយល់អំពីបរមត្ថធម៌ ប៉ុន្តែការសិក្សាព្រះអភិធម្មនេះ នៅខ្វះឧបករណ៍ជាច្រើនទៀតដូចជាគម្ពីរមហាបដ្ឋានជាដើម ពិតណាស់ សូម្បីមានការសិក្សាគម្ពីរមហាបដ្ឋានខ្លះក៏ដោយ តែការសិក្សានោះ មានត្រឹមតែក្នុងកុសលត្តិកមហាបដ្ឋានប៉ុណ្ណោះ បំណែកឯតិកៈដទៃ ៗ មានវេទនាត្តិកមហាបដ្ឋាន, ឬវិបាកត្តិកមហាបដ្ឋានជាដើមទៀត នៅមិនទាន់មានឡើយ ព្រោះហេតុនោះ ខ្ញុំព្រះករុណា ខ្ញុំបាទ អាស្រ័យហេតុនេះឯង ទើបរួបរួមគម្ពីរមហាបដ្ឋាននេះឡើងមក ដើម្បីជាប្រយោជន៍ដល់សិក្ខាកាមទាំងឡាយ ។

ក្នុងការរៀបរៀងសង្កិលិដ្ឋត្តិកមហាបដ្ឋាននេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានអាស្រ័យហេតុខាងដើម គឺ យល់ឃើញថា មានតែការសិក្សាព្រះបរិយត្តិប៉ុណ្ណោះ ជាហេតុនៃការតាំងមាំនៃព្រះសាសនា ទើបបានរួបរួមសៀវភៅនេះឡើងមក ជាឧបករណ៍នៃការសិក្សាដោយអាស្រ័យគម្ពីរព្រះត្រៃបិដកខ្មែរ និងគម្ពីរមហាបដ្ឋានរបស់ព្រះគ្រូធម្មធរសុមន្តនន្ទិកោ ជាដើម ក្នុងការរៀបរៀង ។

ម្យ៉ាងវិញទៀត ការរួបរួមគម្ពីរសង្ខិលិដ្ឋត្ថិកមហាបដ្ឋាននេះ អាចនឹងមាន សេចក្តីភ្លាំងភ្លាត់ ឬ ការខ្វះខាតយ៉ាងណាមួយ សូមខន្តីអភ័យទោស អំពីសម្នាក់បណ្ឌិត ទាំងឡាយ និងជួយកែតម្រូវដើម្បីជាប្រយោជន៍នៃការរួបរួមតទៅ ។

ទីបញ្ចប់នេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រមូលបុណ្យទាំងអស់នេះ ឧទ្ទិសបំពោះ **ក្រុមជំនុំព្រះត្រៃបិដក** និងញាតិក្នុងសង្សារវដ្ត មានអ្នកម្តាយ ***កែវ ពេជ្រសុខុម***ជាដើម ហើយសូមប្រគេនបុណ្យ និងជូនបុណ្យដល់អ្នកដ៏មានគុណទាំងឡាយ ជាពិសេស គឺៈ

១- ព្រះអាចារ្យ**មហាខ្វូន ឧត្តមបញ្ញោ** ជាគ្រូបង្រៀនគម្ពីរបទរូបសិទ្ធិ, វុត្តោទ័យ, និងសុពោធាលង្ការៈជាដើម ។

២- ព្រះអាចារ្យ**មហាភូរិវឌ្ឍកោ** ជាគ្រូបង្រៀនគម្ពីរព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។

៣- លោកគ្រូ**សមពរ បញ្ញាធរ** ជាគ្រូបង្រៀនគម្ពីរព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ, មាតិកា, វិភង្គ, មហាបដ្ឋាន, និងវិសុទ្ធិមគ្គជាដើម ។

សូមពុទ្ធបរិស័ទទាំងអស់ បានចំណែកនៃបុណ្យនេះស្មើ ៗ គ្នា នឹងជាបច្ច័យ នៃការអស់ទៅនៃអាសវក្កិលេសកុំបីអាក់ខានឡើយ ។

សូមអនុមោទនា.....

**ធម្មឃោសិតារាម ហៅតាធក**

ថ្ងៃ ព្រហស្បតិ៍ ៩ កើត ខែចេត្រ ឆ្នាំខាល បត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២៣

**មហាខណ្ឌរ័ត្នខ្មែរ**

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## ៥.សង្កិលិដ្ឋត្តិកៈ

១. ហេតុប្បច្ច័យ ៧ វារៈ ........ ១
២. អារម្មណប្បច្ច័យ ៦ វារៈ ........ ១២
៣. អធិបតិប្បច្ច័យ ៨ វារៈ ........ ២៧
៤. អនន្តរប្បច្ច័យ ៧ វារៈ ........ ៣៩
៥. សមនន្តរប្បច្ច័យ ៧ វារៈ ........ ៤៧
៦. សហជាតប្បច្ច័យ ៩ វារៈ ........ ៤៨
៧. អញ្ញមញ្ញប្បច្ច័យ ៣ វារៈ ........ ៦៦
៨. និស្សយប្បច្ច័យ ១៣ វារៈ ........ ៧៥
៩. ឧបនិស្សយប្បច្ច័យ ៨ វារៈ ........ ៨៣
១០. បុរេជាតប្បច្ច័យ ៣ វារៈ ........ ១១៧
១១. បច្ឆាជាតប្បច្ច័យ ៣ វារៈ ........ ១២៤
១២. អាសេវនប្បច្ច័យ ៣ វារៈ ........ ១២៧
១៣. កម្មប្បច្ច័យ ៧ វារៈ ........ ១៣១
១៤. វិបាកប្បច្ច័យ ៤ វារៈ ........ ១៤១
១៥. អាហារប្បច្ច័យ ៧ វារៈ ........ ១៤៨

១៦. ឥន្ទ្រិយប្បច្ច័យ ៧ វារៈ ...................................................................................១៥៦
១៧. ឈានប្បច្ច័យ ៧ វារៈ ...................................................................................១៦៤
១៨. មគ្គប្បច្ច័យ ៧ វារៈ ...................................................................................១៧២
១៩. សម្បយុត្តប្បច្ច័យ ៣ វារៈ...................................................................................១៨០
២០. វិប្បយុត្តប្បច្ច័យ ៥ វារៈ...................................................................................១៨៤
២១. អត្ថិប្បច្ច័យ ១៣ វារៈ...................................................................................១៩៣
២២. នត្ថិប្បច្ច័យ ៧ វារៈ...................................................................................២២៥
២៣. វិគតប្បច្ច័យ ៧ វារៈ...................................................................................២២៦
២៤. អវិគតប្បច្ច័យ ៧ វារៈ ...................................................................................២២៧

## បករណ៍ជំនួយក្នុងការរៀបរៀងសៀវភៅនេះ

១-គម្ពីរព្រះត្រៃបិដកខ្មែរ

២-គម្ពីរព្រះអដ្ឋកថា

៣-មហាបដ្ឋាន (ព្រះគ្រូធម្មធរសុមន្ត នន្ទិកោ)

# ៥.សង្កិលិដ្ឋត្តិកៈ

បឋមបទ **សង្កិលិដ្ឋសង្កិលេសិកា ធម្មា** ។

ពួកធម៌ដែលសៅហ្មង (គឺ កិលេស និងធម៌ដែលសម្បយុត្តជាមួយគ្នានឹងកិលេស) ទាំងគួរដើម្បីដល់នូវសេចក្ដីសៅហ្មង (គឺ ជាអារម្មណ៍របស់កិលេសបាន) ។

បានដល់ **អកុ. ចិត្ត ១២, ចេ. ២៧** ។

ទុតិយបទ **អសង្កិលិដ្ឋសង្កិលេសិកា ធម្មា** ។

ពួកធម៌ដែលមិនសៅហ្មង (គឺ កិលេសមិនចូលប្រកប) តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង (គឺ ជាអារម្មណ៍របស់កិលេសបាន) ។

បានដល់ **លោកិយកុ ១៧, លោកិយវិបាក ៣២, កិរិយា ២០, ចេ. ៣៨, រូប ២៨** ។

តតិយបទ **អសង្កិលិដ្ឋអសង្កិលេសិកា ធម្មា** ។

ពួកធម៌ដែលមិនសៅហ្មង (គឺ កិលេសមិនចូលប្រកប) ទាំងមិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មង (គឺ មិនជាអារម្មណ៍របស់កិលេស) ។

បានដល់ **លោកុត្តរចិត្ត ៨, ចេ. ៣៦, និងព្រះនិព្វាន** ។

# <u>អធិប្បាយសង្កិលិដ្ឋត្តិកៈ</u>

ឈ្មោះថា **<u>សង្កិលិដ្ឋ</u>** គឺ ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ ព្រោះជាធម៌ដែលប្រកបដោយសង្កិលេស បានដល់ **អកុ. ១២, ចេ. ២៧** ។

ឈ្មោះថា **<u>សង្កិលេសិក</u>** គឺ គួរដើម្បីដល់នូវសេចក្ដីសៅហ្មង ព្រោះគួរដល់នូវសង្កិលេស គឺ ជាអារម្មណ៍ ព្រោះប្រព្រឹត្តទៅដោយមិនឈានកន្លងភាពជាអារម្មណ៍របស់សង្កិលេស ។

បានដល់ **លោកិយ ៨១, ចេ. ៥២, រូប ២៨** ។

ឈ្មោះថា **<u>សង្កិលិដ្ឋសង្កិលេសិក</u>** ព្រោះជាធម៌ដែលសៅហ្មង ដោយការប្រកបជាមួយគ្នានឹងសង្កិលេស និងគួរដើម្បីដល់នូវសេចក្ដីសៅហ្មង គឺជាអារម្មណ៍ ។

ឈ្មោះថា **<u>អសង្កិលិដ្ឋ</u>** គឺ ធម៌ដែលមិនសៅហ្មង (គឺ កិលេសមិនចូលប្រកប) បានដល់ **កុសលចិត្ត ២១, វិបាកចិត្ត ៣៦, កិរិយាចិត្ត ២០, ចេ. ៣៨, រូប ២៨, និព្វាន** ។

ឈ្មោះថា **អ<u>សង្កិលេសិក</u>** គឺ មិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មង គឺ មិនជាអារម្មណ៍របស់កិលេស បានដល់ **លោកុត្តរចិត្ត ៨, ចេ. ៣៦, ព្រះនិព្វាន** ។

ព្រះដ៏មានព្រះភាគទ្រង់សម្ដែងសង្កិលិដ្ឋត្តិកមាតិកានេះ ដើម្បីឱ្យជ្រាបថា ទ្រង់សម្ដែងសភាវៈធម៌របស់បច្ច័យ ២៤ ក្នុងតិកៈនេះ តាមន័យរបស់ “**សង្កិលិដ្ឋត្តិកមាតិកា**” ។

# ៥. សង្កិលិដ្ឋត្តិកៈ

## បញ្ហាវារវិភង្គ  សុទ្ធសង្ខ្យាវារៈ

| | | |
|---|---|---|
| ហេតុយា សត្ត | ហេតុប្បច្ច័យ | មាន ៧ វារៈ |
| អារម្មណេ ឆ | អារម្មណប្បច្ច័យ | មាន ៦ វារៈ |
| អធិបតិយា អដ្ឋ | អធិបតិប្បច្ច័យ | មាន ៨ វារៈ |
| អនន្តរេ សត្ត | អនន្តរប្បច្ច័យ | មាន ៧ វារៈ |
| សមនន្តរេ សត្ត | សមនន្តរប្បច្ច័យ | មាន ៧ វារៈ |
| សហជាតេ នវ | សហជាតប្បច្ច័យ | មាន ៩ វារៈ |
| អញ្ញមញ្ញេ តីណិ | អញ្ញមញ្ញប្បច្ច័យ | មាន ៣ វារៈ |
| និស្សយេ តេរស | និស្សយប្បច្ច័យ | មាន ១៣ វារៈ |
| ឧបនិស្សយេ អដ្ឋ | ឧបនិស្សយប្បច្ច័យ | មាន ៨ វារៈ |
| បុរេជាតេ តីណិ | បុរេជាតប្បច្ច័យ | មាន ៣ វារៈ |
| បច្ឆាជាតេ តីណិ | បច្ឆាជាតប្បច្ច័យ | មាន ៣ វារៈ |
| អាសេវនេ តីណិ | អាសេវនប្បច្ច័យ | មាន ៣ វារៈ |

| | | |
|---|---|---|
| កម្មេ សត្ត | កម្មប្បច្ច័យ | មាន ៧ វារៈ |
| វិបាកេ បត្តារិ | វិបាកប្បច្ច័យ | មាន ៤ វារៈ |
| អាហារេ សត្ត | អាហារប្បច្ច័យ | មាន ៧ វារៈ |
| ឥន្ទ្រិយេ សត្ត | ឥន្ទ្រិយប្បច្ច័យ | មាន ៧ វារៈ |
| ឈានេ សត្ត | ឈានប្បច្ច័យ | មាន ៧ វារៈ |
| មគ្គេ សត្ត | មគ្គប្បច្ច័យ | មាន ៧ វារៈ |
| សម្បយុត្តេ តីណិ | សម្បយុត្តប្បច្ច័យ | មាន ៣ វារៈ |
| វិប្បយុត្តេ បញ្ច | វិប្បយុត្តប្បច្ច័យ | មាន ៥ វារៈ |
| អត្ថិយា តេរស | អត្ថិប្បច្ច័យ | មាន ១៣ វារៈ |
| នត្ថិយា សត្ត | នត្ថិប្បច្ច័យ | មាន ៧ វារៈ |
| វិគតេ សត្ត | វិគតប្បច្ច័យ | មាន ៧ វារៈ |
| អវិគតេ តេរស | អវិគតប្បច្ច័យ | មាន ១៣ វារៈ ។ |

## បប់ បញ្ហាវារវិភង្គ សុទ្ធសង្ខ្យាវារៈ

# ១. ហេតុប្បច្ច័យ ៧ វារៈ

បាលីវិធី ទី. ១

សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ (សំ. → សំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

បាលីអនុវាទ

១. សង្កិលិដ្ឋសង្កិលេសិកា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។

ហេតុទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ ដោយអំណាចនៃហេតុប្បច្ច័យ ។

អកុ.ហេតុ ៣ → អកុ. ១២, បេ. ២៧

បាលីវិធី ទី. ២

សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ (សំ. → អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. សង្កិលិដ្ឋសង្កិលេសិកា ហេតូ ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ហេតុទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ ។

អកុ. ហេតុ ៣ → អកុ. ចិត្តជរូប ១៧

<u>បាលីវិធី ទី. ៣</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ច អសង្កិលិដ្ឋសង្កិលេសិកស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។** (សំ. → សំ. អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស និងដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. សង្កិលិដ្ឋសង្កិលេសិកា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ហេតុទាំងឡាយដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ ។

**អកុ.ហេតុ ៣ → អកុ. ១២, បេ. ២៧, និងចិត្តជរូប ១៧**

<u>បាលីវិធី ទី.៤</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។** (អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

បាលីអនុវាទ

១. អសង្កិលិដ្ឋសង្កិលេសិកា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។

ហេតុទាំងឡាយដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ ។

លោកិយកុសលហេតុ ៣ → លោកិយកុ. ១៧, ចេ. ៣៨, និងកុសលចិត្តជរូប ១៧

លោកិយវិបាកហេតុ ៣ → លោកិយសហេតុកវិ ១៧, ចេ. ៣៥, និងចិត្តជរូប ១៥

កិរិយាហេតុ ៣ → សហេតុកកិរិយា ១៧, ចេ. ៣៥, និងចិត្តជរូប ១៧

២. បដិសន្ធិក្ខណេ អសង្កិលិដ្ឋសង្កិលេសិកា ហេតូ សម្បយុត្តកានំ ខន្ធានំ កដត្តា ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។

ក្នុងខណៈនៃបដិសន្ធិ ហេតុទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់កដត្តារូបទាំងឡាយ ដោយអំណាចនៃហេតុប្បច្ច័យ ។

បដិសន្ធិវិបាកហេតុ ៣ → សហេតុកបដិសន្ធិចិត្ត ១៧, ចេ. ៣៥, និងបដិសន្ធិកម្មជរូប ២០

<u>បាលីវិធី ទី.៥</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។** (អសំ. អសំ. → អសំ. អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

<u>បាលីអនុវាទ</u>

១. **អសង្កិលិដ្ឋអសង្កិលេសិកា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។**

ហេតុទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ ដោយអំណាចនៃហេតុប្បច្ច័យ ។

លោកុត្តរហេតុ ៣ → លោកុត្តរចិត្ត ៨, ចេ. ៣៦

<u>បាលីវិធី ទី.៦</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។** (អសំ. អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អសង្កិលិដ្ឋអសង្កិលេសិកា ហេតូ ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ហេតុទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ ។

**លោកុត្តរហេតុ ៣ → ចិត្តជរូប ១៨** (វៀរ វិញ្ញត្តិរូប ២)

<u>បាលីវិធី ទី.៧</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ច អសង្កិលិដ្ឋអសង្កិលេ-សិកស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។** (អសំ. អសំ. → អសំ. និងអសំ. អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស និងដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយអំណាចនៃហេតុប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អសង្កិលិដ្ឋអសង្កិលេសិកា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ហេតុទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ ។

លោកុត្តរហេតុ ៣ → លោកុត្តរចិត្ត ៨, ចេ. ៣៦, និងចិត្តជរូប ១៥

# ចប់ហេតុប្បច្ច័យ

# ២. អារម្មណប្បច្ច័យ ៦ វារៈ

បាលីវិធី ទី.១

សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ (សំ.→ សំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអារម្មណប្បច្ច័យ ។

បាលីអនុវាទ

១. រាគំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។

បុគ្គលត្រេកអរ រីករាយនឹងរាគៈ ព្រោះប្រារព្ធនូវរាគៈនោះ រាគៈទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆា កើតឡើង ឧទ្ធច្ចៈ កើតឡើង ទោមនស្ស កើតឡើង ។

លោភៈ៨, បេ.២២ → អកុ.១២, បេ.២៧

២. ទិដ្ឋឹ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។

បុគ្គល ត្រេកអរ ភ្លើតភ្លើននឹងទិដ្ឋិ រាគៈ ព្រោះប្រារព្ធនូវទិដ្ឋិនោះ ទើបកើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ឧទ្ធច្ចៈ កើតឡើង, ទោមនស្ស កើតឡើង ។

**លោភៈទិដ្ឋិគតសម្បយុត្ត ៤, បេ. ២១ → អកុ. ១២, បេ. ២៧**

៣. **វិចិកិច្ឆំ អារព្ភ វិចិកិច្ឆា ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធនូវវិចិកិច្ឆា វិចិកិច្ឆា ទើបកើតឡើង, ទិដ្ឋិ កើតឡើង, ឧទ្ធច្ចៈ កើតឡើង, ទោមនស្ស កើតឡើង ។

**មោហៈវិចិកិច្ឆា ១, បេ. ១៥ → អកុ. ៨** (វៀរទិដ្ឋិគតវិប្បយុត្ត ៤), **បេ. ២៦** (មានះ)

៤. **ឧទ្ធច្ចំ អារព្ភ ឧទ្ធច្ចំ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធឧទ្ធច្ចៈ ឧទ្ធច្ចៈ ទើបកើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ទោមនស្ស កើតឡើង ។

**មោហៈឧទ្ធច្ចៈ ១, បេ. ១៥ → អកុ. ៨,** (វៀរលោភៈទិដ្ឋិគតវិប្បយុត្ត ៤) **បេ. ២៦** (វៀរមានះ)

៥. **ទោមនស្សំ អារព្ភ ទោមនស្សំ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធទោមនស្ស ទោមនស្ស ទើបកើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ឧទ្ធច្ចៈ កើតឡើង ។

**ទោសៈ ២, បេ. ២២ → អកុ. ៨** (វៀរទិដ្ឋិគតវិប្បយុត្ត ៤), **បេ. ២៦** (វៀរមានះ)

<u>បាលីវិធី ទី.២</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ** ។ (សំ. → អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេសដោយអំណាចនៃអារម្មណប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អរិយា បហីនេ កិលេសេ បច្ចវេក្ខន្តិ វិក្ខម្ភិតេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ** ។

ព្រះអរិយបុគ្គលទាំងឡាយ ពិចារណានូវកិលេសដែលលះបង់ហើយ ពិចារណានូវកិលេសដែលគ្របសង្កត់ហើយ ដឹងច្បាស់នូវកិលេសដែលធ្លាប់សន្សំទុកហើយ ក្នុងកាលមុន ។

**កិលេស ១០ → មហាកុ. ៨, បេ. ៣៣, មហាកិ. ៨, បេ. ៣៣**

**២. សង្កិលិដ្ឋសង្កិលេសិកេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**

ព្រះអរិយបុគ្គលទាំងឡាយ ឃើញច្បាស់នូវខន្ធទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ថាជាអនិច្ចំ ទុក្ខំ អនត្តា ។

**អកុ. ១២, បេ. ២៧ → មហាកុ. ៨, បេ. ៣៣, មហាកិ. ៨, បេ. ៣៣**

**៣. ចេតោបរិយញ្ញាណេន សង្កិលិដ្ឋសង្កិលេសិកចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។**

បុគ្គលទាំងឡាយ ដឹងច្បាស់នូវចិត្តរបស់បុគ្គលដែលដល់ព្រម ដោយចិត្តដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយចេតោបរិយញ្ញាណ ។

**អកុ. ១២, បេ. ២៧ → ចេតោបរិយញ្ញាណអភិញ្ញា. ២, បេ.៣០**

**៤. សេក្ខា វា បុថុជ្ជនា វា សង្កិលិដ្ឋសង្កិលេសិកេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ កុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី ឃើញច្បាស់នូវខន្ធទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ថាជាអនិច្ចំ ទុក្ខំ អនត្តា កាលបើកុសលរលត់ទៅហើយ វិបាក កើតឡើងដោយភាពជាតទារម្មណ៍ ។

**អកុ. ១២, បេ. ២៧ → តទាលម្ពណចិត្ត ១១, បេ. ៣៣**

៥. សង្កិលិដ្ឋសង្កិលេសិកេ ខន្ធេ អស្សាទេត្តិ អភិនន្ទតិ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ អកុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។

ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី ត្រេកអរ ភ្លើតភ្លើននូវខន្ធទាំងឡាយដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស រាគៈ ក៏កើតឡើង ទិដ្ឋិ កើតឡើង វិចិកិច្ឆា កើតឡើង ឧទ្ធច្ចៈ កើតឡើង ទោមនស្ស កើតឡើង កាលបើអកុសលរលត់ទៅហើយ វិបាក ក៏កើតឡើង ដោយភាពជាតទារម្មណ៍ ។

**អកុ. ១២, បេ. ២៧ → តទាលម្ពណបិត្ត ១១, បេ. ៣៣**

៦. សង្កិលិដ្ឋសង្កិលេសិកា ខន្ធា ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

ខន្ធទាំងឡាយដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ អនាគតំសញ្ញាណ អាវជ្ជនៈ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

**អកុ. ១២, បេ. ២៧ → អភិញ្ញា. ២, បេ. ៣០, មនោទ្វារាវជ្ជនបិត្ត ១, បេ. ១១**

<u>បាលីវិធី ទី.៣</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ** ។ (អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអារម្មណប្បច្ច័យ ។

<u>បាលីអនុវាទ</u>

១. **ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ បច្ចវេក្ខតិ** ។

បុគ្គលឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពិចារណានូវទាន សីល និងឧបោសថនោះ

**មហាកុ. ៨, បេ. ៣៦ → មហាកុ. ៨, បេ. ៣៣, មហាកិ. ៨, បេ. ៣៣**

២. **បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ** ។

បុគ្គល ពិចារណានូវកម្ម ដែលខ្លួនប្រព្រឹត្តល្អហើយ ក្នុងកាលមុន ។

**មហាកុ. ៨, បេ. ៣៨ → មហាកុ. ៨, បេ. ៣៣, មហាកិ. ៨, បេ. ៣៣**

៣. **ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ** ។

បុគ្គល ចេញចាកឈានហើយ ពិចារណាអង្គឈាន ។

មហគ្គតកុ. ៩, បេ. ៣៥ → មហាកុ. ៨, បេ. ៣៣

មហគ្គតកិ. ៩, បេ. ៣៥ → មហាកិ. ៨, បេ. ៣៣

៤. អរិយា គោត្រភុំ បច្ចវេក្ខន្តិ វោទានំ បច្ចវេក្ខន្តិ ។

ព្រះអរិយបុគ្គលទាំងឡាយ ពិចារណាគោត្រភូ ពិចារណាវោទាន ។

មហាកុ. សម្បយុត្ត. ៤, បេ. ៣៣ → មហាកុ. ៨, បេ. ៣៣, មហាកិ. ៨, បេ. ៣៣

៥. ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ សោតំ ...ឃានំ...ជិវ្ហំ...កាយំ...រូបេ...សទ្ទេ...គន្ធេ ...រសេ...ផោដ្ឋព្វេ...វត្ថុំ... អសង្កិលិដ្ឋសង្កិលេសិកេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។

ព្រះអរិយបុគ្គលទាំងឡាយ ឃើញច្បាស់នូវចក្ខុ ថាជាអនិច្ចំ ទុក្ខំ អនត្តា ឃើញច្បាស់នូវសោតៈ...ឃានៈ...ជិវ្ហា...កាយៈ...រូប...សំឡេង...ក្លិន....រស...ផោដ្ឋព្វៈ...វត្ថុ ខន្ធទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ថាជាអនិច្ចំ ទុក្ខំ អនត្តា ។

ឱឡារិករូប ១២, ហទយវត្ថុ
លោកិយកុសល ១៧, លោកិយវិបាក ៣២,
កិរិយា ២០, បេ. ៣៨
} មហាកុ. ៨, បេ. ៣៣, មហាកិ. ៨, បេ. ៣៣

៦. ទិព្វេន ចក្ខុនា រូបំ បស្សន្តិ, ទិព្វាយ សោតធាតុយា សទ្ទំ សុណន្តិ ។

ព្រះអរិយបុគ្គលទាំងឡាយ ឃើញរូប ដោយទិព្វចក្ខុ ឮសំឡេង ដោយទិព្វសោតធាតុ ។

រូបារម្មណ៍ → ទិព្វចក្ខុអភិញ្ញាកុ. ១, បេ. ៣០, អភិញ្ញាកិ. ១, បេ. ៣០

សទ្ទារម្មណ៍ → ទិព្វសោតអភិញ្ញាកុ. ១, បេ. ៣០, អភិញ្ញាកិ. ១, បេ. ៣០

៧. ចេតោបរិយញ្ញាណេន អសង្កិលិដ្ឋសង្កិលេសិកចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។

ព្រះអរិយបុគ្គលទាំងឡាយ ដឹងច្បាស់នូវចិត្តរបស់បុគ្គលដែលដល់ព្រម ដោយចិត្តដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយចេតោបរិយញ្ញាណ ។

| | |
|---|---|
| លោកិយកុសល ១៧, បេ. ៣៨ | ចេតោបរិយញ្ញាណអភិញ្ញា ២, បេ. ៣០ |
| លោកិយវិបាក ៣២, បេ. ៣៥ | |
| កិរិយា ២០, បេ. ៣៥ | |

៨. អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនស្ស អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនស្ស អារម្មណប្បច្ចយេន បច្ចយោ ។

អាកាសានញ្ចាយតនៈ ជាបច្ច័យដល់វិញ្ញាណញ្ចាយតនៈ, អាកិញ្ចញ្ញាយតនៈ ជាបច្ច័យដល់នេវសញ្ញានាសញ្ញាយតនៈ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

អាកាសានញ្ចាយតនកុ. ១, បេ. ៣០
- →វិញ្ញាណញ្ចាយតនកុ. ១, បេ. ៣០
- →វិញ្ញាណញ្ចាយតនវិ. ១, បេ. ៣០
- →វិញ្ញាណញ្ចាយតនកិ. ១, បេ. ៣០

អាកាសានញ្ចាយតនកិ. ១, បេ. ៣០ → វិញ្ញាណញ្ចាយតនកិរិយា ១, បេ. ៣០

អាកិញ្ចញ្ញាយតនកុ. ១, បេ. ៣០ → នេវសញ្ញានាសញ្ញាយតន. ៣, បេ. ៣០

អាកិញ្ចញ្ញាយតនកិ. ១, បេ. ៣០ → នេវសញ្ញានាសញ្ញាយតនកិ. ១, បេ. ៣០

៩. រូបាយតនំ ចក្ខុវិញ្ញាណស្ស, សទ្ទាយតនំ សោតវិញ្ញាណស្ស, គន្ធាយតនំ ឃានវិញ្ញាណស្ស, រសាយតនំ ជិវ្ហាវិញ្ញាណស្ស, ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។

រូបាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណ, សទ្ទាយតនៈ ជាបច្ច័យដល់សោតវិញ្ញាណ, គន្ធាយតនៈ ជាបច្ច័យដល់ឃានវិញ្ញាណ, រសាយតនៈ ជាបច្ច័យដល់ជិវ្ហាវិញ្ញាណ, ផោដ្ឋព្វាយតនៈ ជាបច្ច័យដល់កាយវិញ្ញាណ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

បញ្ចារម្មណ៍ → ទ្វិបញ្ចវិញ្ញាណចិត្ត ១០, បេ. ៧

១០. អសង្កិលិដ្ឋសង្កិលេសិកា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

ខន្ធទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ អនាគតំសញ្ញាណ អាវជ្ជនៈ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

លោកិយកុសល ១៧, បេ. ៣៨ }
លោកិយវិបាក ៣២, បេ. ៣៥ } អភិញ្ញា ២, បេ. ៣០
កិរិយា ២០, បេ. ៣៥, រូប ២៨ } មនោទ្វារាវជ្ជនៈចិត្ត១, បេ.១១

<u>បាលីវិធី ទី.៤</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។** (អសំ. → សំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអារម្មណប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលឱ្យទាន សមាទានសីល ធ្វើឧបោសថកម្មហើយ រមែងត្រេកអរ ភ្លើតភ្លើននូវទានជាដើមនោះ រាគៈ ព្រោះប្រារព្ធនូវទានជាដើមនោះ ក៏កើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ឧទ្ធច្ចៈ កើតឡើង, ទោមនស្ស កើតឡើង ។

មហាកុ.៨, បេ.៣៦ → អកុ.១២, បេ.២៧

២.បុព្វេ សុចិណ្ណានិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។

បុគ្គលត្រេកអរ រីករាយ នឹងកុសលកម្មទាំងឡាយ ដែលខ្លួនសន្សំទុកហើយ ក្នុងកាលមុន រាគៈ ព្រោះប្រារព្ធនូវកម្មនោះ ទើបកើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ឧទ្ធច្ចៈ កើតឡើង, ទោមនស្ស កើតឡើង ។

មហាកុ.៨, បេ.៣៨ → អកុ.១២, បេ.២៧

៣. ឈានា វុដ្ឋហិត្វា ឈានំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ឈានេ បរិហីនេ វិប្បដិសារិស្ស ទោមនស្សំ ឧប្បជ្ជតិ ។

បុគ្គលចេញចាកឈានហើយ រមែងត្រេកអរ ភ្លើតភ្លើននូវឈាន ព្រោះប្រារព្ធនូវឈាននោះ រាគៈ ទើបកើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ឧទ្ធច្ចៈ កើតឡើង, កាលបើឈានវិនាស ហើយ ទោមនស្ស ក៏កើតឡើង ដល់បុគ្គលដែលមានវិប្បដិសារី (សភាពក្តៅក្រហាយនៃចិត្ត) ។

មហគ្គតកុ.៩, បេ.៣៥ → អកុ.១២, បេ.២៧

៤. បក្ខុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ សោតំ...ឃានំ...ជិវ្ហំ...កាយំ...រូបេ...សទ្ទេ...គន្ធេ...រសេ...ផោដ្ឋព្វេ...

**វត្ថុំ... អសង្កិលិដ្ឋសង្កិលេសិកេ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គល ត្រេកអរ ភ្លើតភ្លើន នឹងចក្ខុ ព្រោះប្រារព្ធចក្ខុនោះ រាគៈ រមែងកើត ទិដ្ឋិ រមែងកើត វិចិកិច្ឆា រមែងកើត ឧទ្ធច្ចៈ រមែងកើត ទោមនស្ស រមែងកើត រមែងត្រេកអរ ភ្លើតភ្លើននូវសោតៈ ...ឃានៈ...ជិវ្ហា...កាយៈ...រូប...សំឡេង...ក្លិន...រស...ផោដ្ឋព្វ...វត្ថុ ខន្ធទាំងឡាយដែលមិនត្រូវកិលេស ធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ព្រោះប្រារព្ធនូវធម៌ទាំងឡាយមានសោតៈ ជាដើមនោះ រាគៈ ក៏កើតឡើង, ទិដ្ឋិ កើតឡើង, វិចិកិច្ឆា កើតឡើង, ឧទ្ធច្ចៈ កើតឡើង, ទោមនស្ស កើតឡើង ។

**ឱឡារិករូប ១២, ហទយវត្ថុ ១,**
**លោកិយកុសល ១៧, លោកិយវិបាក ៣២,** } **អកុ. ១២, បេ. ២៧**
**កិរិយា ២០, បេ. ៣៨**

<u>បាលីវិធី ទី.៤</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។** (អសំ.អសំ. → អសំ.អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអារម្មណប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. និព្វានំ មគ្គស្ស ផលស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

និព្វាន ជាបច្ច័យដល់មគ្គ ដល់ផល ដោយអំណាចនៃអារម្មណប្បច្ច័យ ។

**និព្វាន → មគ្គចិត្ត ៤, ចេ. ៣៦, ផលចិត្ត ៤, ចេ. ៣៦**

<u>បាលីវិធី ទី.៦</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។** (អសំ.អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអារម្មណប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ផលំ បច្ចវេក្ខន្តិ និព្វានំ បច្ចវេក្ខន្តិ ។**

ព្រះអរិយបុគ្គលទាំងឡាយ ចេញចាកមគ្គហើយ ពិចារណាមគ្គ ពិចារណាផល ពិចារណាព្រះនិព្វាន ។

**អរហត្តមគ្គ ១, អរហត្តផល ១, ចេ. ៣៦, និព្វាន → មហាកិ.សម្បយុត្ត. ៤, ចេ. ៣៣**

**មគ្គជាន់ទាប ៣, ចេ.៣៦, ផលជាន់ទាប ៣, ចេ. ៣៦, និព្វាន → មហាកុ.សម្បយុត្ត. ៤, ចេ. ៣៣**

២. **និព្វានំ គោត្រភុស្ស វោទានស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។**

និព្វានជាបច្ច័យដល់គោត្រភូ ដល់វោទាន ដល់អាវជ្ជនៈ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

**និព្វាន → មហាកុ.សម្បយុត្ត. ៤, ចេ. ៣៣, មនោទ្វារាវជ្ជនចិត្ត ១, ចេ. ១១**

៣. **អរិយា ចេតោបរិយញ្ញាណេន អសង្កិលិដ្ឋអសង្កិលេសិកចិត្តសមង្គិស្ស ចិត្តំ ជានន្តិ អសង្កិលិដ្ឋអសង្កិលេសិកា ខន្ធា ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។**

ព្រះអរិយបុគ្គលទាំងឡាយ ដឹងច្បាស់នូវចិត្តរបស់បុគ្គលដែលដល់ព្រមដោយចិត្តដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ អនាគតំសញ្ញាណ អាវជ្ជនៈ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

លោកុត្តរចិត្ត ៨, ប េ. ៣៦ → អភិញ្ញាចិត្ត ២, ប េ. ៣០

និងមនោទ្វារាវជ្ជនចិត្ត ១, ប េ. ១១

## ចប់ អារម្មណប្បច្ច័យ

# ៣. អធិបតិប្បច្ច័យ ៨ វារៈ

## អធិបតិប្បច្ច័យ មាន ២ បច្ច័យ គឺៈ

## អារម្មណាធិបតិប្បច្ច័យ និងសហជាតាធិបតិប្បច្ច័យ

បាលីវិធី ទី. ១

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។** (សំ.→ សំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។

បាលីអនុវាទ

១. **អារម្មណាធិបតិ រាគំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ទិដ្ឋឹ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ អធិបតិប្បច្ចយេន បច្ចយោ ។**

អារម្មណាធិបតិ គឺ បុគ្គល ធ្វើរាគៈឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើនរាគៈ ធ្វើរាគៈនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង, បុគ្គល ធ្វើទិដ្ឋិឱ្យ

ជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើន, រាគៈ ធ្វើទិដ្ឋិនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបឡើងកើត ទិដ្ឋិ ក៏កើតឡើង ជាបច្ច័យដោយអំណាចនៃអធិបតិប្បច្ច័យ ។

លោភៈ ៨, បេ. ២២ → លោភៈ ៨, បេ. ២២

២. **សហជាតាធិបតិ សង្កិលិដ្ឋសង្កិលេសិកាធិបតិ សម្បយុត្តកានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។**

ឯសហជាតាធិបតិ គឺ អធិបតីដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ ដោយអំណាចនៃអធិបតិប្បច្ច័យ ។

**អកុ.អធិបតី ៣ → អកុ. ១០** (វៀរមោហៈ២) **បេ. ២៦** (វៀរវិចិកិច្ឆា)

<u>បាលីវិធី ទី. ២</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ** ។ (សំ. → អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. សហជាតាធិបតិ សង្កិលិដ្ឋសង្កិលេសិកាធិបតិ ចិត្តសមុដ្ឋានានំ រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។**

សហជាតាធិបតិ បានដល់ អធិបតីដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអធិបតិប្បច្ច័យ ។

**អកុ.អធិបតី ៣ → ចិត្តជរូប ១៧**

<u>បាលីវិធី ទី. ៣</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ច អសង្កិលិដ្ឋសង្កិលេសិកស្ស ច ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។** (សំ.→ សំ. និង អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស និងដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. សហជាតាធិបតិ សង្កិលិដ្ឋសង្កិលេសិកាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។**

សហជាតាធិបតិ បានដល់ អធិបតីដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអធិបតិប្បច្ច័យ ។

**អកុ.អធិបតី ៣ → អកុ. ១០** (វៀរមោហៈ២), **លោ. ២៦** (វៀរវិចិកិច្ឆា), និង**ចិត្តជរូប ១៧**

<u>បាលីវិធី ទី. ៤</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។**

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។

<u>បាលីអនុវាទ</u>

១. **អារម្មណាធិបតិ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ គរុំ កត្វា បច្ចវេក្ខតិ ។**

អារម្មណាធិបតិ គឺ បុគ្គលឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើនូវកម្មនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ (គឺជាទីគោរព) ហើយពិចារណា ។

**មហាកុ. ៨, បេ. ៣៦ → មហាកុ. ៨, បេ. ៣៣**

២. **បុព្វេ សុចិណ្ណានិ គរុំ កត្វា បច្ចវេក្ខតិ ។**

បុគ្គល ធ្វើនូវកុសលកម្ម ដែលសន្សំទុកហើយ ក្នុងកាលមុន ឱ្យធ្ងន់ ហើយពិចារណា ។

**មហាកុ. ៨, បេ. ៣៨ → មហាកុ. ៨, បេ. ៣៣**

៣. **ឈានា វុដ្ឋហិត្វា ឈានំ គរុំ កត្វា បច្ចវេក្ខតិ ។**

បុគ្គល ចេញចាកឈាន ធ្វើឈាននោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយពិចារណា ។

**មហគ្គតកុ. ៩, បេ. ៣៥ → មហាកុ. ៨, បេ. ៣៣**

៤. **សេក្ខា គោត្រភុំ គរុំ កត្វា បច្ចវេក្ខន្តិ, វោទានំ គរុំ កត្វា បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ធ្វើនូវគោត្រភូឱ្យធ្ងន់ ហើយពិចារណា, ធ្វើនូវវោទានឱ្យធ្ងន់ ហើយពិចារណា ។

មហាកុ.សម្បយុត្ត. ៤, បេ. ៣៣ → មហាកុ. ៨, បេ. ៣៣

**៤. សហជាតាធិបតិ អសង្កិលិដ្ឋសង្កិលេសិកាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។**

ឯសហជាតាធិបតិ គឺ អធិបតីដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអធិបតិប្បច្ច័យ ។

**អធិបតី ៤ → លោកិយកុ. ១៧, បេ. ៣៨, សាធិបតិកិរិយាជវនៈ ១៧, បេ. ៣៥**

**និងចិត្តជរូប ១៧**

<u>បាលីវិធី ទី. ៤</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ** ។ (អសំ → សំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អារម្មណាធិបតិ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

អារម្មណាធិបតិ គឺ បុគ្គល ឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើនូវកុសលកម្មនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើន រាគៈ ធ្វើនូវកុសលកម្មនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង ។

មហាកុ. ៨, បេ. ៣៦ → លោភៈ ៨, បេ. ២២

**២. បុព្វេ សុចិណ្ណានិ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

បុគ្គល ធ្វើនូវកុសលកម្ម ដែលបានសន្សំទុកហើយ ក្នុងកាលមុន ឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើន, រាគៈ ធ្វើនូវកុសលកម្មនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង ។

មហាកុ. ៨, បេ. ៣៨ → លោភៈ ៨, បេ. ២២

**៣. ឈានា វុដ្ឋហិត្វា ឈានំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

បុគ្គល ចេញចាកឈាន ធ្វើឈានឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើន រាគៈ ធ្វើឈាននោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង ។

មហគ្គតកុ. ៩, បេ. ៣៥ → លោភៈ ៨, បេ. ២២

**៤. ចក្ខុំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ សោតំ...ឃានំ...ជិវ្ហំ...កាយំ...រូបេ...សទ្ទេ...គន្ធេ...រសេ...ផោដ្ឋព្វេ...វត្ថុំ អសង្កិលិដ្ឋសង្កិលេសិកេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

បុគ្គល ធ្វើនូវចក្ខុឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើន, រាគៈ ធ្វើចក្ខុនោះឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង, ធ្វើនូវសោតៈ...ឃានៈ...ជិវ្ហា...កាយៈ...រូប...សំឡេង...ក្លិន...រស...ផោដ្ឋព្វៈ...វត្ថុ ខន្ធទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយត្រេកអរ ភ្លើតភ្លើន រាគៈ ធ្វើនូវខន្ធជា-ដើមនោះ ឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ទើបកើតឡើង ទិដ្ឋិក៏កើតឡើង ។

**ឱឡារិករូប ១២, ហទយវត្ថុ ១,**
**លោកិយកុ. ១៧, បេ. ៣៨, លោកិយវិ. ៣១** } **លោភៈ ៨, បេ. ២២**
(វៀរទុក្ខកាយ), **បេ. ៣៥, កិរិយា ២០, បេ. ៣៥**

<u>បាលីវិធី ទី.៦</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។** (អសំ.អស. → អសំ.អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។

<u>បាលីអនុវាទ</u>

១. **អារម្មណាធិបតិ និព្វានំ មគ្គស្ស ផលស្ស អធិបតិប្បច្ចយេន បច្ចយោ ។**

អារម្មណាធិបតិ គឺ ព្រះនិព្វាន ជាបច្ច័យដល់មគ្គ ជាបច្ច័យដល់ផល ដោយអំណាចនៃអធិបតិប្បច្ច័យ ។

**និព្វាន → មគ្គចិត្ត ៤, ចេ. ៣៦, ផលចិត្ត ៤, ចេ. ៣៦**

២. **សហជាតាធិបតិ អសង្កិលិដ្ឋអសង្កិលេសិកាធិបតិ សម្បយុត្តកានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។**

ឯសហជាតាធិបតិ គឺ អធិបតីដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ ដោយអំណាចនៃអធិបតិប្បច្ច័យ ។

លោកុត្តរអធិបតី ៤ → លោកុត្តរចិត្ត ៨, បេ. ៣៦

<u>បាលីវិធី ទី. ៧</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។** (អសំ.អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។

<u>បាលីអនុវាទ</u>

**១. អារម្មណាធិបតិ អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា បច្ចវេក្ខន្តិ ។**

អារម្មណាធិបតិ គឺ ព្រះអរិយបុគ្គលទាំងឡាយ ចេញចាកមគ្គ ធ្វើមគ្គឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយពិចារណា ។

**មគ្គជាន់ទាប ៣, បេ. ៣៦ → មហាកុ.សម្បយុត្ត. ៤, បេ. ៣៣**

**អរហត្តមគ្គ ១, បេ. ៣៦ → មហាកិ.សម្បយុត្ត. ៤, បេ. ៣៣**

**២. ផលំ គរុំ កត្វា បច្ចវេក្ខន្តិ ។**

ព្រះអរិយបុគ្គលទាំងឡាយ ធ្វើផលឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយពិចារណា ។

ផលជាន់ទាប ៣, បេ. ៣៦ → មហាកុ.សម្បយុត្ត. ៤, បេ. ៣៣

អរហត្តផល ១, បេ. ៣៦ → មហាកិ.សម្បយុត្ត. ៤, បេ. ៣៣

៣. **និព្វានំ គរុំ កត្វា បច្ចវេក្ខន្តិ** ។

ព្រះអរិយបុគ្គលទាំងឡាយ ធ្វើនិព្វានឱ្យជាអារម្មណ៍យ៉ាងធ្ងន់ ហើយពិចារណា ។

និព្វាន → មហាកុ.សម្បយុត្ត. ៤, បេ. ៣៣, និងមហាកិ.សម្បយុត្ត. ៤, បេ. ៣៣

៤. **និព្វានំ គោត្រភុស្ស វោទានស្ស អធិបតិប្បច្ចយេន បច្ចយោ** ។

ព្រះនិព្វាន ជាបច្ច័យដល់គោត្រភូ និងវោទាន ដោយអំណាចនៃអធិបតិប្បច្ច័យ ។

និព្វាន → មហាកុ.សម្បយុត្ត. ៤, បេ. ៣៣

៥. សហជាតាធិបតិ អសង្កិលិដ្ឋអសង្កិលេសិកាធិបតិ **ចិត្តសមុដ្ឋានានំ រូបានំ អធិបតិប្បច្ចយេន បច្ចយោ** ។

ឯសហជាតាធិបតិ គឺ អធិបតីដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអធិបតិប្បច្ច័យ ។

**លោកុត្តរអធិបតី ៤ → ចិត្តជរូប ១៥** (វៀរវិញ្ញត្តិរូប ២)

<u>បាលីវិធី ទី. ៨</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស ច អសង្កិលិដ្ឋសង្កិលេ-សិកស្ស ច ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។** (អសំ.អសំ. → អសំ.អសំ. និងអសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស និងដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអធិបតិប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. សហជាតាធិបតិ អសង្កិលិដ្ឋអសង្កិលេសិកាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។**

សហជាតាធិបតិ គឺ អធិបតីដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអធិបតិប្បច្ច័យ ។

លោកុត្តរអធិបតី ៤ → លោកុត្តរចិត្ត ៨, ចេ. ៣៦, ចិត្តជរូប ១៥

**ចប់ អធិបតិប្បច្ច័យ**

# ៤. អនន្តរប្បច្ច័យ ៧ វារៈ

<u>បាលីវិធី ទី. ១</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ** ។ (សំ.→ សំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. បុរិមា បុរិមា សង្កិលិដ្ឋសង្កិលេសិកា ខន្ធា បច្ឆិមានំ បច្ឆិមានំ សង្កិលិដ្ឋសង្កិលេសិកានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ** ។

ខន្ធទាំងឡាយដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេសដែលកើតមុន ៗ ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេសដែលកើតក្រោយ ៗ ដោយអំណាចនៃអនន្តរប្បច្ច័យ ។

**អកុ. ១២, បេ. ២៧ ដែលកើតមុន ៗ → អកុ. ១២, បេ. ២៧ ដែលកើតក្រោយ ៗ**

(វៀរជវនៈដួងចុងក្រោយ) (វៀរជវនៈដួងដំបូង)

<u>បាលីវិធី ទី. ២</u>

សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ (សំ. → អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុវាទ</u>

១. សង្កិលិដ្ឋសង្កិលេសិកា ខន្ធា វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

ខន្ធទាំងឡាយដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់វុដ្ឋានៈ (គឺ តទាលម្ពណចិត្ត ឬភវង្គចិត្ត) ដោយអំណាចនៃអនន្តរប្បច្ច័យ ។

**អកុ. ១២, បេ. ២៧ ផ្លូវបុងក្រោយ → តទាលម្ពណចិត្ត ១១, បេ. ៣៣**

**ឬ ភវង្គចិត្ត ១៩, បេ. ៣៥ តាមសមគួរ ។**

<u>បាលីវិធី ទី. ៣</u>

អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ (អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. បុរិមា បុរិមា អសង្កិលិដ្ឋសង្កិលេសិកា ខន្ធា បច្ឆិមានំ បច្ឆិមានំ អសង្កិលិដ្ឋសង្កិលេសិកានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។**

ខន្ធទាំងឡាយដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេសដែលកើតមុន ៗ ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេសដែលកើតក្រោយ ៗ ដោយអំណាចនៃអនន្តរប្បច្ច័យ ។

| | |
|---|---|
| លោកិយកុ. ១៧, ចេ. ៣៨ ដែលកើតមុន ៗ | លោកិយកុ. ១៧, ចេ. ៣៨ ដែលកើតក្រោយ ៗ |
| លោកិយវិ. ៣២, ចេ. ៣៥ ដែលកើតមុន ៗ | លោកិយកុ. ៣២, ចេ. ៣៥ ដែលកើតក្រោយ ៗ |
| កិរិយា ១៩, ចេ. ៣៥ ដែលកើតមុន ៗ | កិរិយា ១៩, ចេ. ៣៥ ដែលកើតក្រោយ ៗ |
| (វៀរបញ្ចទ្វារាវជ្ជនចិត្ត) | (វៀរបញ្ចទ្វារាវជ្ជនចិត្ត) |

២. អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស អាវជ្ជនា អសង្កិលិដ្ឋសង្កិលេសិកានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។

អនុលោម ជាបច្ច័យដល់គោត្រភូ អនុលោម ជាបច្ច័យដល់វោទាន: អាវជ្ជន: ជាបច្ច័យដល់ខន្ធទាំងឡាយដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

មហាកុ.សម្បយុត្ត. ៤, បេ. ៣៣ → មហាកុ.សម្បយុត្ត. ៤, បេ. ៣៣

(ខណៈធ្វើអនុលោម) (ខណៈធ្វើគោត្រភូ ឬ វោទាន)

បញ្ចទ្វារាវជ្ជនចិត្ត ១, បេ. ១០ → ទ្វិបញ្ចវិញ្ញាណចិត្ត. ១០, បេ. ៧

មនោទ្វារាវជ្ជនចិត្ត ១, បេ. ១១ → មហាកុ. ៨, បេ. ៣៨, កាមកិរិយាជវន: ៩, បេ. ៣៥

មនោទ្វារាវជ្ជនចិត្ត ១, បេ. ១១ → កាមភវង្គ ១០, បេ. ៣៣ (ក្នុងវោដ្ឋព្វនវារ:)

<u>បាលីវិធី ទី. ៤</u>

អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ (អសំ.→ សំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អាវជ្ជនា សង្កិលិដ្ឋសង្កិលេសិកានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។**

អាវជ្ជនៈ ជាបច្ច័យដល់ខន្ធទាំងឡាយដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

**មនោទ្វារាវជ្ជនចិត្ត ១, បេ. ១១ → ជវនៈដួងខាងដើមរបស់អកុ. ១២, បេ. ២៧**

<u>បាលីវិធី ទី. ៤</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ**។ (អសំ. → អសំ.អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. គោត្រភុ មគ្គស្ស វោទានំ មគ្គស្ស អនុលោមំ ផលសមាបត្តិយា និរោធា វុដ្ឋហន្តស្ស នេវសញ្ញានាសញ្ញាយតនំ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។**

គោត្រភូ ជាបច្ច័យដល់មគ្គ, វោទាន ជាបច្ច័យដល់មគ្គ, អនុលោម ជាបច្ច័យដល់ផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនជ្ឈានរបស់បុគ្គលដែលចេញចាកនិរោធសមាបត្តិ ជាបច្ច័យដល់ផលសមាបត្តិ ដោយអំណាចនៃអនន្តរប្បច្ច័យ ។

មហាកុ.សម្បយុត្ត. ៤, ចេ. ៣៣ → សោតាបត្តិមគ្គចិត្ត ១, ចេ. ៣៦

(ខណៈធ្វើគោត្រភូ) (ក្នុងសោតាបត្តិមគ្គវិថី)

មហាកុ.សម្បយុត្ត. ៤, ចេ. ៣៣ → មគ្គខាងលើ ៣, ចេ. ៣៦

(ខណៈធ្វើវោទាន) (ក្នុងមគ្គវិថីខាងលើ ៣)

មហាកុ.សម្បយុត្ត. ៤, ចេ. ៣៣ → ផលខាងក្រោម ៣, ចេ. ៣៦

(ខណៈធ្វើអនុលោមដួងចុងក្រោយ) (ក្នុងផលវិថីសមាបត្តិខាងក្រោម ៣)

មហាកិ.សម្បយុត្ត. ៤, ចេ. ៣៣ → អរហត្តផល ១, ចេ. ៣៦

(ខណៈធ្វើអនុលោមដួងចុងក្រោយ) (ក្នុងអរហត្តផលសមាបត្តិវិថី)

នេវ. កុ. ១, ចេ.៣០ → អនាគាមិផល ១, ចេ. ៣៦

(ដួងទី ២) (ក្នុងនិរោធសមាបត្តិវិថីរបស់ព្រះអនាគាមី)

នេវ.កិ. ១, ចេ. ៣០ → អរហត្តផល ១, ចេ. ៣៦

(ដួងទី ២) (ក្នុងនិរោធសមាបត្តិវិថីរបស់ព្រះអរហន្ត)

<u>បាលីវិធី ទី.៦</u>

**អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ** ។ (អសំ.អសំ. → អសំ.អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុភាទ</u>

**១. បុរិមា បុរិមា អសង្កិលិដ្ឋអសង្កិលេសិកា ខន្ធា បច្ឆិមានំ បច្ឆិមានំ អសង្កិលិដ្ឋ-អសង្កិលេសិកានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ** ។

ខន្ធទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេសដែលកើតមុន ៗ ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍នៃកិលេសដែលកើតក្រោយ ៗ ដោយអំណាចនៃអនន្តរប្បច្ច័យ ។

**មគ្គចិត្ត ៤, ចេ. ៣៦ → ផលចិត្ត ៤, ចេ. ៣៦ ដែលកើតក្រោយ ៗ**

**២. មគ្គោ ផលស្ស ផលំ ផលស្ស អនន្តរប្បច្ចយេន បច្ចយោ** ។

មគ្គជាបច្ច័យដល់ផល ផលជាបច្ច័យដល់ផល ដោយអំណាចនៃអនន្តរប្បច្ច័យ ។

មគ្គចិត្ត ៤, បេ. ៣៦ → ផលចិត្ត ៤, បេ. ៣៦ (ក្នុងមគ្គវិថី)

ផលចិត្ត ៤, ៣៦ ដែលកើតមុន ៗ → ផលចិត្ត ៤, បេ. ៣៦ ដែលកើតក្រោយ ៗ

(ក្នុងមគ្គវិថី និងផលសមាបត្តិវិថី)

<u>បាលីវិធី ទី.៧</u>

អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ និងមិនជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃអនន្តរប្បច្ច័យ ។

<u>បាលីអនុវាទ</u>

១. ផលំ វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

ផល ជាបច្ច័យដល់វុដ្ឋានៈ (គឺ ភវង្គ) ដោយអំណាចនៃអនន្តរប្បច្ច័យ ។

ផលចិត្ត ៤, បេ. ៣៦ → តិហេតុកភវង្គ ១៣, បេ. ៣៥

## ចប់ អនន្តរប្បច្ច័យ

# ៥. សមនន្តរប្បច្ច័យ ៧ វារៈ

<u>បាលីវិធី ទី.១</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស សមនន្តរប្បច្ចយេន បច្ចយោ ។** (សំ. → សំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃសមនន្តរប្បច្ច័យ ។

សម្តែងដូចគ្នានឹងអនន្តរប្បច្ច័យ ៧ វារៈ

## បប់ សមនន្តរប្បច្ច័យ

(សូម្បីនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ សម្តែងដូចគ្នានឹងអនន្តរប្បច្ច័យ ព្រោះមាន ៧ វារៈដូចគ្នា)

# ៦. សហជាតប្បច្ច័យ ៩ វារៈ

## បាលីវិធី ទី.១

សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។ (សំ. → សំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ដោយអំណាចនៃសហជាតប្បច្ច័យ ។

## បាលីអនុវាទ

១. សង្កិលិដ្ឋសង្កិលេសិកោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។

តយោ ខន្ធា ឯកស្ស ខន្ធស្ស សហជាតប្បច្ចយេន បច្ចយោ ។

ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។

ខន្ធ ១ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ៣ ដោយអំណាចនៃសហជាតប្បច្ច័យ ។

ខន្ធ ៣ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ១ ដោយអំណាចនៃសហជាតប្បច្ច័យ ។

ខន្ធ ២ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ២ ដោយអំណាចនៃសហជាតប្បច្ច័យ ។

**អកុ. ១២, បេ. ២៧ → អកុ. ១២, បេ. ២៧**

<u>**បាលីវិធី ទី.២**</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ** ។ (សំ. → អសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃសហជាតប្បច្ច័យ ។

<u>**បាលីអនុភាទ**</u>

**១. សង្កិលិដ្ឋសង្កិលេសិកា ខន្ធា ចិត្តសមុដ្ឋានានំ រូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

ខន្ធទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតប្បច្ច័យ ។

**អកុ. ១២, បេ. ២៧ → ចិត្តជរូប ១៧**

<u>បាលីវិធី ទី.៣</u>

**សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ សង្កិលិដ្ឋសង្កិលេសិកស្ស ច អសង្កិលិដ្ឋសង្កិលេសិកស្ស ច ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។** (សំ. → សំ. និងអសំ)

ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស និងធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃសហជាតប្បច្ច័យ ។

<u>បាលីអនុវាទ</u>

១. **សង្កិលិដ្ឋសង្កិលេសិកា ខន្ធា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

ខន្ធទាំងឡាយ ដែលត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ និងជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់សម្បយុត្តខន្ធទាំងឡាយ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតប្បច្ច័យ ។

**អកុ. ១២, ប. ២៧ → អកុ. ១២, ប. ២៧, និងចិត្តជរូប ១៧**

<u>បាលីវិធី ទី.៤</u>

**អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។** (អសំ. → អសំ)

ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ធម៌ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ដោយអំណាចនៃសហជាតប្បច្ច័យ ។

<u>បាលីអនុវាទ</u>

**១. អសង្កិលិដ្ឋសង្កិលេសិកោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។**

**តយោ ខន្ធា ឯកស្ស ខន្ធស្ស សហជាតប្បច្ចយេន បច្ចយោ ។**

**ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។**

ខន្ធ ១ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ៣ ដោយអំណាចនៃសហជាតប្បច្ច័យ ។

ខន្ធ ៣ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្ដៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ១ ដោយអំណាចនៃសហជាតប្បច្ច័យ ។

ខន្ធ ២ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ២ ដោយអំណាចនៃសហជាតប្បច្ច័យ ។

លោកិយកុ. ១៧, បេ. ៣៨ → លោកិយកុ. ១៧, បេ. ៣៨

លោកិយវិ. ៣២, បេ. ៣៥ → លោកិយវិ. ៣២, បេ. ៣៥

កិរិយា ២០, បេ. ៣៥ → កិរិយា ២០, បេ. ៣៥

២. អសង្កិលិដ្ឋសង្កិលេសិកោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

តយោ ខន្ធា ឯកស្ស ខន្ធស្ស ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

ខន្ធ ១ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ៣ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតប្បច្ច័យ ។

ខន្ធ ៣ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ១ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតប្បច្ច័យ ។

ខន្ធ ២ ដែលមិនត្រូវកិលេសធ្វើឱ្យសៅហ្មងក្តៅក្រហាយ តែជាអារម្មណ៍របស់កិលេស ជាបច្ច័យដល់ខន្ធ ២ និងដល់រូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតប្បច្ច័យ ។

**លោកិយកុ. ១៧, ចេ. ៣៨ → លោកិយកុ. ១៧, ចេ. ៣៨, និងចិត្តជរូប ១៧**

**លោកិយវិ. ១៨, ចេ. ៣៥ → លោកិយវិ. ១៨, ចេ. ៣៥, និងចិត្តជរូប ១៥**

(វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០, អរូបវិបាក ៤)

**កិរិយា ២០, ចេ. ៣៥ → កិរិយា ២០, ចេ. ៣៥, និងចិត្តជរូប ១៧**

៣. **បដិសន្ធិក្ខណេ អសង្កិលិដ្ឋសង្កិលេសិកោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ កដត្តា ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

